# ព្រះពុទ្ធសាសនា និង បរិស្ថាន

## ឯកសារបណ្ដុះបណ្ដាលការអប់រំបរិស្ថាន
## សំរាប់ព្រះភិក្ខុសង្ឃ និង ដូនជី

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥៤៣

២៦៣.
៧

២៦៣.៧

# ព្រះពុទ្ធសាសនា និង បរិស្ថាន

## ឯកសារបណ្តុះបណ្តាលការអប់រំបរិស្ថាន

## សំរាប់ព្រះភិក្ខុសង្ឃ និង ដូនជី

បោះពុម្ពលើកទី ១

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

រួមសហការជាមួយក្រុមការងារអង្គការក្រៅរដ្ឋាភិបាល

គម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ

គ.ស. ១៩៩៩

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៤៤៣៨/២០០០

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh        www.elibraryofcambodia.org**

**Buddhism and the Environment**
*A Tool for Headmonks to Train Monks and Nuns*

First edition
Phnom Penh, Cambodia, 1999

Published by the Buddhist Institute
in cooperation with the NGO Working Group
for Monk Environmental Education Project (MEEP)
and with the support of UNDP-ETAP.

# សមាសភាពគណៈកម្មការ
# ក្រុមអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ

## គណៈអធិបតីកិត្តិយស

សម្តេចព្រះសង្ឃរាជ ទេព វង្ស

សម្តេចព្រះសង្ឃរាជ ប៊ួរ គ្រី

**ទីប្រឹក្សា**

សម្តេចព្រះមហាឃោសានន្ទ

ព្រះភិក្ខុ យស ហ៊ុត ខេមចារោ

**គណៈប្រតិបត្តិ**

ប្រធាន

ព្រះភិក្ខុ ហ៊ៀម តិចឆេង *Santi Sena*

អនុប្រធាន

ព្រះភិក្ខុ ស៊ុយ សៀម *BFD*

លេខាធិការ

លោក ហាញ់ ចំរុង *BSA*

**សមាជិក**

លោក យាន លី *APDCE*

លោក ស៊ុន សន *Samakithor*

លោក សុវណ្ណ ណារៈ *SHP*

លោក ភុំ ផាវ៉ាត់ *BDASE*

លោក អៀម ពិសិដ្ឋ *CEPA*

លោក អ៊ុក អុនណារ៉ុង *HRDP*

លោក ស្លុង ប៉ាល់ *BSSA*

អ្នកស្រី ទៅ ម៉ូរ៉ែម *KBSC*

លោក សែម ធុល *FAKP*

លោក តឿ វាសនា *Mlup Baitong*

# ព្រះពុទ្ធសាសនា និង បរិស្ថាន

## ឯកសារបណ្តុះបណ្តាលការអប់រំបរិស្ថាន

## សំរាប់ព្រះភិក្ខុសង្ឃ និង ដូនជី

**ទីប្រឹក្សា**

ព្រះភិក្ខុ បណ្ឌិត អូម៉ាលប៉េ
សោភិត ថេរោ

បណ្ឌិត ភីធ័រ យ៉ាឡាយប៉ាប់

បណ្ឌិត សម្ពោធ សែនគុន

បណ្ឌិត ទិន ពន្លក

លោក អ៊ុង ប៊ុនធឿន

**គណៈកម្មការត្រួតពិនិត្យ**

ឯ.ឧ. ឈន អៀម

ព្រះភិក្ខុ ពៀម គឹមតេង

លោក ឱម ខែម

**បកប្រែនិងកែសម្រួល :**

លោក យឹម ដុក

លោក ហាក់ ធី

លោក អ៊ុង ប៊ុនធឿន

**គណៈកម្មការនិពន្ធ និងរៀបរៀង**

លោក អ៊ុង ប៊ុនធឿន

លោក ហាញ់ ចំរុង

អ្នកស្រី ពៅ ម៉ូរ៉ែម

លោក ហាក់ ធី

លោក យ៉ន សុវណ្ណា

**វាយកុំព្យូទ័រ**

លោក ហាញ់ ចំរុង

លោក ហាក់ ធី

# បញ្ជីមាតិកា

**ចំណងជើង** **ទំព័រ**

**សេចក្ដីផ្ដើម** ..................................................................................១

**ផ្នែកទី ១ : ការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ** ............................៧

- មេរៀនទី ១ : ព្រះធម៌ និងបរិស្ថាន ..................................................៩
- មេរៀនទី ២ : អត្ថន័យនៃពាក្យវត្ត.............................................១៣
- មេរៀនទី ៣ : ការចៀសវាងការបំពុល ឬភាពកខ្វក់ តាមរយៈព្រះវិន័យ ..............................................១៧
- មេរៀនទី ៤ : កិច្ចវត្តប្រចាំថ្ងៃរបស់ព្រះសង្ឃធ្វើឱ្យ បរិស្ថានស្អាតបរិសុទ្ធ ..............................................២០
- មេរៀនទី ៥ : ការបង្រៀនបរិស្ថានតាមរយៈព្រះភិក្ខុសង្ឃ...............២៥

**ផ្នែកទី ២ : ការអប់រំបរិស្ថានសំរាប់ដូនជី និង តាជី** ...................២៩

- មេរៀនទី ១ : ការអភិវឌ្ឍ និងសារប្រយោជន៍ នៃមជ្ឈមណ្ឌលសហគមន៍វត្តសិក្សាធម៌.................៣១

# សេចក្តីផ្តើម

## សូមថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ

ក្នុងឋានៈជាមេដឹកនាំ ព្រះចៅអធិការមួយអង្គនៅប្រទេសកម្ពុជា ត្រូវបានគេជ្រើសរើសឡើង ដើម្បីផ្តួចផ្តើមគំនិតក្នុងការសិក្សា និងធ្វើសកម្មភាពនានា សំរាប់រក្សាការពារបរិស្ថានឱ្យបានស្អាតជានិច្ចនៅតាមវត្ត និងសហគមន៍ជុំវិញ ដែលចំណុះជើងវត្ត ។ ប្រសិនបើព្រះតេជព្រះគុណ-លោកអ្នក និងសហសេវិកថ្នាក់ដឹកនាំសង្ឃ និងគ្រហស្ថរបស់ព្រះតេជព្រះគុណ-លោកអ្នក ដែលនៅតាមវត្តដទៃ បានទទួលការបណ្តុះបណ្តាលអំពី " **ព្រះពុទ្ធសាសនា និង បរិស្ថាន** " ទាំងអស់គ្នានោះ នឹងមានការយកចិត្តទុកដាក់អនុវត្តតាម នូវអ្វីដែលព្រះតេជព្រះគុណ-លោកអ្នកបានសិក្សា និងយល់ដឹង ។ នោះមានន័យថា គុណភាពនៃការរស់នៅប្រចាំថ្ងៃ ឬគុណភាពនៃជីវិតនៅតាមសហគមន៍ របស់ព្រះតេជព្រះគុណ-លោកអ្នក ក៏ដូចជានៅទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូលដែរ នឹងទទួលបានលក្ខណៈល្អប្រសើរឡើងជាក់ជាមិនខាន ។

គម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ របស់ក្រុមការងារនៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដឹកនាំដោយព្រះតេជព្រះគុណ **ញៀម គឹមតេង** បានធ្វើការ ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងធម្មការ និងសាសនា ក្រសួងបរិស្ថាន ហើយនិងពុទ្ធសាសនបណ្ឌិត្យ ក្នុងបំណងដើម្បីលើកកំពស់ និងកែលំអគុណភាពនៃជីវិត នៅក្នុងប្រទេសជាតិរបស់យើង តាមរយៈការអនុវត្តនូវគោលការណ៍ និងមាគ៌ាព្រះពុទ្ធសាសនា ។ ដោយមានការជួយឧបត្ថម្ភខាងផ្នែកបច្ចេកទេស ពីអង្គការសហប្រជាជាតិផងនោះ គម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ បានបង្កើតឯកសារសិក្សាបានចំនួន ២ មុខ រួចមក

ហើយ ដើម្បីជួយដល់ព្រះតេជព្រះគុណ-លោកអ្នក នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ។ អត្ថបទសិក្សាស្តីពីព្រះពុទ្ធសាសនា និងបរិស្ថានទាំងនេះ បានផ្តោតទៅលើក្រុមគោលដៅបីក្រុម គឺ :

❶ ក្រុមព្រះសង្ឃ

❷ ក្រុមដូនជី និងឧបាសក-ឧបាសិកាវស់នៅក្នុងវត្ត

❸ ក្រុមសហគមន៍វត្ត ( ប្រជាពលរដ្ឋតាមភូមិឃុំ ឬសង្កាត់ដែលមានទំនាក់ទំនង ឬចំណុះជើងវត្ត) ។

អត្ថបទសិក្សាទី ១ មានចំណងជើងថា " **សម្រែកព្រៃឈើ** " ដែលបានរៀបរៀងឡើង ក្នុងគោលបំណងសំរាប់សិក្សា និងប្រើប្រាស់ ដោយក្រុមគោលដៅទាំងអស់ក្រោមការដឹកនាំដោយគ្រូឧទ្ទេសមួយរូប (មានព្រះតេជព្រះគុណ-លោកអ្នក ឬក៏នរណាម្នាក់ទៀត ដែលព្រះតេជព្រះគុណ-លោកអ្នកបានចាត់តាំងឡើង) ។ ការណែនាំខ្លះៗ ក្នុងការប្រើប្រាស់សៀវភៅ " **សម្រែកព្រៃឈើ** " គឺមានបង្ហាញស្រាប់ នៅក្នុងផ្នែកអារម្ភកថានៃអត្ថបទសិក្សានោះ ។ កូនសៀវភៅ ដែលព្រះតេជព្រះគុណ-លោកអ្នកកំពុងកាន់នឹងដៃនេះ ជាអត្ថបទសិក្សាពិសេសថ្មីមួយថែមទៀត សំរាប់ភិក្ខុសង្ឃ និងដូនជីដែលរស់នៅតាមវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ដើម្បីឱ្យព្រះសង្ឃ និងដូនជីទាំងនោះមានលទ្ធភាពកាន់តែប្រសើរឡើងៗ ក្នុងការបំរើ និងដឹកនាំប្រជាពលរដ្ឋទូទៅ ។

សហគមន៍ព្រះសង្ឃ ជាធម្មតាជាកំលាំងស្នូលនៃវប្បធម៌ និងសង្គមដ៏ខ្លាំងក្លាមួយនៅក្នុងសង្គមរបស់យើង ក៏ដូចជាសង្គមរបស់បណ្តាប្រទេសជិតខាងយើងដែរ ហើយយើងមានក្តីសង្ឃឹមផងដែរថា អត្ថបទនេះ ប្រាកដជានឹងជួយលើកកំពស់ការយល់ដឹងរបស់ព្រះសង្ឃ ស្តីពីទំនាក់ទំនងរវាងពុទ្ធសាសនា និងបរិស្ថានជាក់ជាមិនខាន ។ វត្តអារាម និងទីសក្ការៈដ៏ល្អល្អះឥតខ្ចោះដទៃទៀត ត្រូវបានគេកសាងជាថ្មីឡើងវិញ ក្រោយសម័យកាល

ដ៏ខ្មៅងងឹត នាពេលថ្មីៗកន្លងផុតទៅនេះ ហើយជាថ្មីម្តងទៀត មានយុវជនជាច្រើន នៅទូទាំងប្រទេស បានចូលខ្លួនមកបួសជាសង្ឃ ជាបណ្តើរៗឡើងវិញដែរ ។ ក្រៅពីកំណើនខាងតួលេខព្រះសង្ឃនោះ កិច្ចប្រឹងប្រែងជាច្រើនទៀត ត្រូវបានធ្វើឡើង ដើម្បីកែលំអគុណភាពនៃជីវិត របស់ព្រះភិក្ខុសង្ឃថែមទៀត ។ ការអភិវឌ្ឍខាងបញ្ញាស្មារតីនៃព្រះសង្ឃជាសេចក្តីត្រូវការយ៉ាងធំធេងមួយនៅក្នុងជួរព្រះសង្ឃ ។ ដូចដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានពុទ្ធដីកាយ៉ាងដូច្នេះថា :

" **អត្តានំ បច្ចវេក្ខិតព្វំ** "

ប្រែមកថា : *" យើងជាភិក្ខុសង្ឃត្រូវធ្វើខ្លួនឱ្យសុភាពរាបសារ ដើម្បីយល់ឱ្យច្បាស់នូវចំណុចខ្សោយផ្ទាល់របស់យើង "* ។

ម្ល៉ោះហើយ សេចក្តីត្រូវការមួយបានកើតឡើង សំរាប់ព្រះភិក្ខុសង្ឃចាស់វស្សាជាង និងជាទីគោរពដ៏ខ្ពង់ខ្ពស់ ដូចជាព្រះតេជព្រះគុណជា **ថេរៈ** ឬជា **ព្រះមហាថេរ** ជាដើម ក្នុងការខិតខំប្រឹងប្រែងជាថ្មីម្តងទៀត ដើម្បីបណ្តុះបណ្តាលព្រះសង្ឃជា **អន្តេវាសិក** ជំនាន់ក្រោយៗទៀត តាមកាលវេលាដ៏សមគួរ ។

ការសិក្សាមុខវិជ្ជាផ្សេងៗ នៅតាមសាលាពុទ្ធិកសិក្សា ឬធម្មវិន័យ និងការសូត្រព្រះធម៌ គឺមានសារសំខាន់ចាំបាច់ក៏ពិតមែន ក៏ប៉ុន្តែវាមិនគ្រប់គ្រាន់ទេ នៅក្នុងការប្រតិបត្តិតាមព្រះពុទ្ធសាសនានៅក្នុងសង្គម ។ ព្រះភិក្ខុសង្ឃទាំងឡាយ ក៏ត្រូវតែបង្ហាញការប្រព្រឹត្តខ្លួនជាគំរូគេ ដែលនឹងជះឥទ្ធិពលទៅលើគំនិតមារយាទប្រកបដោយសីលធម៌ របស់គ្រហស្ថរស់នៅតាមសហគមន៍ផងដែរ ។ ជាថ្មីម្តងទៀត វាមានសារសំខាន់ផងដែរ ចំពោះព្រះភិក្ខុ-សង្ឃ ដើម្បីអភិវឌ្ឍមនុស្សជាតិ និងបរិស្ថានសង្គម-វប្បធម៌ ឱ្យមានសុខភាពល្អ ដូចដែលធ្លាប់មានតាំងពីអតីតកាលមក ។ ព្រះភិក្ខុសង្ឃត្រូវតែតស៊ូ បង្កើតវត្តអារាមជាថ្មីឡើង

វិញរបស់ព្រះអង្គ ដូចគ្នាទៅនឹងមជ្ឈមណ្ឌលសហគមន៍ ឱ្យប្រកបដោយសោភណភាព និង សន្តិភាព ដែលបំរើប្រជាពលរដ្ឋទាំងពួង នៅក្នុងសេចក្តីត្រូវការនៃជីវិត ប្រកបដោយ សីលធម៌ និងផ្លូវលោកដូច្នេះដែរ ។ ដើម្បីទទួលបានមកវិញនូវកិត្តិគុណ ដែលធ្លាប់មានពី អតីតកាល ភិក្ខុសង្ឃខ្មែរត្រូវតែធ្វើការរួមគ្នាជាធ្លុងមួយ (**សមានធម្មិកំ**) និងមើលឱ្យឃើញ វែងឆ្ងាយ (**ទីឃទស្សិន**) ។ ដូចដែលព្រះសម្មាសម្ពុទ្ធ ទ្រង់មានពុទ្ធដីកាយ៉ាងដូច្នេះថា :

" **អន្ធការេន ឱនទ្ធា បទីបំ គវេសថ .....** "

ប្រែថា : " *នេះគឺជាពេលត្រូវអុជប្រទីបនៃវិជ្ជា*

*ដើម្បីកំចាត់អន្ធការភាពនៃអវិជ្ជា...* " ។

ក្នុងឋានៈជាគ្រូអាចារ្យ ឬជាគ្រូឧទ្ទេសម្នាក់ ស្តីពីទស្សនវិជ្ជាព្រះពុទ្ធសាសនា និង បរិស្ថាន នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ជំហានដ៏មានសារសំខាន់ជាងគេបំផុត សំរាប់កិច្ចការរបស់ព្រះតេជព្រះគុណ-លោកអ្នក គឺត្រូវលើកកំពស់ស្មារតីកែលំអ និងអភិវឌ្ឍ ឬពង្រីកសកម្មភាពសិក្សា នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ។ វិធីដ៏មាន ប្រយោជន៍មួយ ដើម្បីចាប់ផ្តើមនោះ គឺការកែលំអ និងការផ្តើមបើក ឬបង្កើតឱ្យមាន បណ្ណាល័យ តាមវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នកផ្ទាល់តែម្តង ។ បណ្ណាល័យវត្តបែប នេះ គួរតែបើកចំហឱ្យបានទូលំទូលាយ ដល់ព្រះភិក្ខុសង្ឃគ្រប់ឋានៈ ដូនជី តាជី និង ប្រជាពលរដ្ឋទាំងអស់រស់នៅក្នុងសហគមន៍ ព្រោះថាបណ្ណាល័យវត្តជាមជ្ឈមណ្ឌលធនធាន និងសិក្សាស្រាវជ្រាវមួយ អំពី *ព្រះពុទ្ធសាសនា វប្បធម៌ខ្មែរ បរិស្ថាន* និង *ការអភិវឌ្ឍ សហគមន៍* ។ ដោយមានការបណ្តុះបណ្តាលបន្តិចបន្តួច និងមានជំនួនទានល្អៗផងនោះ ភិក្ខុ សង្ឃនៅក្នុងវត្ត អាចចាត់ចែង និងបំរើការងារជាបណ្ណារក្សបាន ។ ការផ្តួចផ្តើមគំនិតទាំង នេះ នឹងលើកទឹកចិត្តដល់ភិក្ខុសង្ឃ ដូនជី តាជី និងប្រជាពលរដ្ឋទូទៅ ដែលស្វះស្វែងរក

ឬស្រែកឃ្លានចំណេះដឹង និងការអភិវឌ្ឍបញ្ញាស្មារតីរបស់ខ្លួន ដើម្បីស្រាវជ្រាវនៅក្នុងមជ្ឈមណ្ឌលសិក្សានេះ ដែលអាចត្រូវកែលំអជារៀងរាល់ពេល នៅទន្ទឹមពេលដែលផលប្រយោជន៍ និងសេចក្តីត្រូវការនានាក្នុងសហគមន៍ ចេះតែកើនឡើងឥតឈប់ឈរ ។ ការរៀបចំ និងកសាងវត្តឡើងវិញ ក្នុងឋានៈជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនោះ គួរតែពង្រឹងឡើងវិញ តាមកម្មវិធីមួយ ដើម្បីអភិវឌ្ឍការប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនា ហើយនិងជីវិតសតិបញ្ញា ជាពិសេសសំរាប់ព្រះភិក្ខុសង្ឃទាំងឡាយ ។ សកម្មភាពនេះអាចធ្វើបានតាមរយៈការប្រជុំធ្វើសមាធិប្រចាំថ្ងៃម្តង១ នៅក្នុងព្រះវិហារ ។ ដូនជី តាជី ព្រមទាំងឧបាសក-ឧបាសិកា ក៏អាចចូលរួមក្នុងការតាំងសមាធិនេះបានដែរ ។

នៅក្នុងបរិបទនេះ សារសំខាន់នៃសកម្មភាពប្រចាំថ្ងៃរបស់ព្រះសង្ឃ ត្រូវការឱ្យគេដៅបញ្ជាក់ឱ្យបានច្បាស់លាស់ ។ កាលបើភាពជាគំរូគេលាន់ឮខ្លាំងជាងពាក្យសំដីនោះ ព្រះសង្ឃត្រូវតែបង្ហាញការប្រតិបត្តិរបស់ខ្លួន ប្រកបដោយសីលធម៌ជាគំរូគេ ដល់សង្គមគ្រហស្ថ ។ ដូចដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រៀនប្រដៅយ៉ាងដូច្នេះថា :

**"អត្តានមេវ បឋមំ បដិរូបេ និវេសយេ..."**

ប្រែថា : *"ជាបឋម បុគ្គលគប្បីធ្វើខ្លួនឯង*

*ឱ្យតាំងនៅក្នុងភាពដ៏សមគួរសិន"* ។

នេះជាការសិក្សា និងការដឹកនាំខាងផ្លូវចិត្ត ដែលព្រះតេជព្រះគុណ-លោកអ្នក និងព្រះភិក្ខុសង្ឃចាស់វស្សាដទៃទៀត នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក អាចអនុវត្តតាមក្នុងការកែលំអបរិស្ថាន ដែលព្រះតេជព្រះគុណ-លោកអ្នកកំពុងរស់នៅ ។

ដើម្បីជាជំនួយក្នុងកិច្ចខិតខំប្រឹងប្រែងជាមួយនឹងព្រះភិក្ខុ និងដូនជី តាជី នៅក្នុង

វត្តរបស់ព្រះតេជព្រះគុណ-លោកអ្នកនោះ យើងខ្ញុំព្រះករុណាសូមផ្តល់ការណែនាំ និងការបង្រៀនខ្លះៗ និងការអនុវត្តមួយចំនួន មាននៅក្នុងកូនសៀវភៅនេះស្រាប់ ដែលព្រះតេជព្រះគុណ-លោកអ្នកអាចប្រើបាន ។ ព្រះតេជព្រះគុណ-លោកអ្នកអាចដឹកនាំការបង្រៀនមេរៀនទាំងនេះដល់ព្រះសង្ឃ នៅក្រោយពេលសំដែង ឬសូត្របាដិមោក្ខ និងតាមរយៈ **ព្រះធម្មទេសនា** ឬក៏តាមការជ្រើសរើសរបស់ព្រះតេជព្រះគុណ-លោកអ្នកចង់បាន ។ សំរាប់ដូនជី និងតាជីវិញ យើងខ្ញុំសូមស្នើឱ្យបង្កើត *ក្រុមសិក្សាព្រះធម៌* ឬ *មជ្ឈមណ្ឌលសហគមន៍វត្តសិក្សាធម៌* សំរាប់ពួកគាត់ ប្រសិនបើពួកគាត់ពុំទាន់មានមជ្ឈមណ្ឌលសិក្សាបែបនោះនៅឡើយ ។ ក្រុមសិក្សាបែបនេះអាចបញ្ចូលមេរៀន និងសកម្មភាពមួយចំនួនដែលអាចជួយលើកកំពស់គុណភាពនៃការរស់នៅ ក្នុងសហគមន៍វត្ត ។ តាមរយៈវិធី ឬមធ្យោបាយនេះ ការសិក្សា និងការអនុវត្ត តាងនាមព្រះពុទ្ធសាសនា និងបរិស្ថានទាំងមូល ដែលប្រកបដោយសុខភាពល្អ នឹងទទួលផលសំរេចបានទាំងស្រុង ។

## ការអភិរក្សធនធានធម្មជាតិ គឺរក្សាការពារបរិស្ថាន

# ផ្នែកទី ១

# ការអប់រំបរិស្ថាន

# សំរាប់ព្រះសង្ឃខ្មែរ

មេរៀនទី ១ : ព្រះធម៌ និង បរិស្ថាន

មេរៀនទី ២ : អត្ថន័យនៃពាក្យវត្ត

មេរៀនទី ៣ : ការចៀសវាងការបំពុល ឬភាពកខ្វក់ តាមរយៈព្រះវិន័យ

មេរៀនទី ៤ : កិច្ចវត្តប្រចាំថ្ងៃរបស់ព្រះសង្ឃធ្វើឱ្យបរិស្ថាន ស្អាតបរិសុទ្ធ

មេរៀនទី ៥ : ការបង្រៀនបរិស្ថានតាមរយៈព្រះភិក្ខុសង្ឃ

# ១. ព្រះធម៌ និង បរិស្ថាន

**១. វត្ថុបំណង** : ដើម្បីឱ្យព្រះភិក្ខុសង្ឃយល់ពីទំនាក់ទំនងរវាងព្រះធម៌ និងបរិស្ថាន ។

**២. លំហាត់ចបង្រៀន** :

មានមហន្តរាយមួយបានកើតឡើង នៅភាគខាងត្បូងនៃប្រទេសអ៊ីតាលីកាលពីថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៩៨ កន្លងទៅនេះ ។ ប្រពន្ធ័ឃោសនា បានរាយការណ៍ឱ្យដឹងថា នេះជាលើកទីមួយហើយ ដែលប្រជាពលរដ្ឋទទួលការរងគ្រោះពីបាតុភូតជំនន់ដីភក់ ឬកំអែភក់ដែលទាញយកជីវិតមនុស្សជាង ១០០ នាក់ ។ តំបន់ទីក្រុងបានលិចកប់ក្នុងភក់ជំរៅជិត ៣ ម៉ែត ហើយនិងបានបំផ្លាញលំនៅឋាន និងអគារធំៗអស់ជាច្រើនខ្នងទៀត ។ អ្នកជំនាញបរិស្ថាន បានបង្ហាញពីហេតុប៉ះពាល់ទាំងនេះថា គឺបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើនៅតំបន់ខ្ពង់រាបនៅជុំវិញទីក្រុង ក្រោមលេសថា " ដើម្បីអភិវឌ្ឍ" ។ ការកាប់បំផ្លាញព្រៃឈើនេះ បានដកចេញនូវរបាំងធម្មជាតិ ក្នុងការទប់ទល់នឹងការហូរកំអែភក់ បណ្តាលមកពីការធ្លាក់ភ្លៀងយ៉ាងខ្លាំងនោះ ។

ព្រះធម៌ ឬពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ មានន័យថាជា *ច្បាប់ធម្មជាតិ* ។ ចំណុចដ៏សំខាន់របស់ព្រះធម៌ គឺ **អរិយសច្ចៈ** ទាំង ៤ ហើយនិង **អដ្ឋង្គិកមគ្គ** ទាំង ៨ ដើម្បីត្រាស់ដឹង ដែលចាប់ផ្តើមឡើងដោយការប្រតិបត្តិតាម **បញ្ចសីល** ឬសីល ៥ ។ ព្រះពុទ្ធសាសនាមានទស្សនៈថា *មនុស្សជាតិជាផ្នែកមួយនៃធម្មជាតិ* ។ ដូច្នេះ *ដោយការរំលោភ ឬកេងប្រវ័ញ្ចលើធម្មជាតិ នោះមានន័យថា មនុស្សនឹងរំលោភបំពាន ឬកេងប្រវ័ញ្ចលើខ្លួនឯងដែរ* ។ ប្រសិនបើធម្មជាតិ ត្រូវគេបំផ្លាញ នោះមនុស្សលោក មិនអាចរស់រានមានជីវិតបានឡើយ ។ រាល់ជីវិត និងភាវៈទាំងឡាយនៅលើផែនដីនេះ រមែងតែមានអន្តរសម្ពន្ធ

នឹងគ្នា និងតែងមានលក្ខខណ្ឌរវាងគ្នាជានិច្ច ។ នេះបង្ហាញថាគឺមាន *ហេតុ* និង *ផល* ឬ *ផលវិបាក* ពីអំពើ ឬហេតុការណ៍អ្វីមួយ ដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងធម្មជាតិ ។ វាក៏បានបង្ហាញថា ការប្រព្រឹត្តរបស់មនុស្ស ទោះមាន ឬគ្មានសីលធម៌ក្តី រមែងតែជះឥទ្ធិពលទៅដល់ដំណើរប្រព្រឹត្តរបស់ធម្មជាតិជានិច្ច ។

ព្រះសម្មាសម្ពុទ្ធ បានពន្យល់របៀបនៃកិច្ចការរបស់ព្រះធម៌យ៉ាងដូច្នេះថា :

" **ធម្មោ ហវេ រក្ខតិ ធម្មចារី** "

ដែលមានន័យថា : " *មនុស្សដែលការពារព្រះធម៌ ឬប្រព្រឹត្តស្រប តាមព្រះធម៌ រមែងត្រូវបានព្រះធម៌ការពារ* " ។

រឿងនេះមានន័យថា ប្រសិនបើព្រះតេជព្រះគុណ-លោកអ្នក មិនដើរតាមគន្លងព្រះធម៌ទេ ឬក៏ប្រឆាំងនឹងព្រះធម៌ នោះក៏មានន័យថា *ព្រះតេជព្រះគុណ-លោកអ្នក នឹងប្រឆាំងធម្មជាតិដែរ* ហើយហៅរកការបំផ្លិចបំផ្លាញ សំរាប់ព្រះតេជព្រះគុណ-លោកអ្នកដោយខ្លួនឯង និងអ្នកដទៃទៀតជាមិនខានឡើយ ។ សញ្ញាណនេះ បានបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងព្រះធម៌ សកម្មភាពរបស់មនុស្សជាតិ ហើយនិងបរិស្ថាន ។ សោកនាដកម្មនៅប្រទេសអ៊ីតាលី បានផ្តល់ឱ្យយើងនូវមេរៀនដ៏ឈឺចាប់មួយថា តើភាពល្ងង់ខ្លៅ ( *អវិជ្ជា* ) នៃព្រះធម៌ រមែងនាំទៅរកការឈឺចាប់ ឬទុក្ខសោកដ៏ជាសំណាង ចំពោះអំពើអាក្រក់របស់មនុស្សជាតិនេះវិញយ៉ាងដូចម្តេច ។ យើងទាំងអស់គ្នាត្រូវតែយល់ពីបរិស្ថានក្នុងគំនិត ឬន័យដ៏ទូលំទូលាយ មួយរួមមានផ្នែកសំខាន់ៗទាំងបី ដែលជាធាតុមានទំនាក់ទំនងរវាងគ្នាជានិច្ច ពោលគឺមាន បរិស្ថានធម្មជាតិ វប្បធម៌ ( ឬ សង្គម ) និងមនុស្ស ។

ដូច្នេះ ព្រះភិក្ខុសង្ឃអាចជួយបង្កើតជីវិតដ៏ល្អប្រសើរមួយ សំរាប់ខ្លួនព្រះអង្គផ្ទាល់ វត្តអារាម ព្រមទាំងសំរាប់សហគមន៍ទាំងមូល ដែលនៅឆ្ងាយៗផងដែរ ដោយការលើក

តម្កើងបរិស្ថានមួយត្រឹមត្រូវល្អ ពោលគឺស្អាត និងប្រកបដោយសុខភាពល្អ ។ ព្រះភិក្ខុសង្ឃ និងប្រជាពលរដ្ឋទាំងពួង រមែងតែទទួលនូវរបស់សំខាន់ៗ ដែលជាតម្រូវការចាំបាច់សំរាប់រស់រាន ដូចជា អាហារ ថ្នាំពេទ្យ ទីជម្រក និងសំលៀកបំពាក់ពីបរិស្ថានធម្មជាតិ និងសង្គម ។ ម្ល៉ោះហើយ ការថែរក្សា និងការពារខ្លួនរបស់យើងផ្ទាល់ មានន័យថា យើងថែរក្សា និងការពារផែ្នក ឬធាតុដទៃទៀតនៃបរិស្ថានផងដែរ ។ ហើយកិច្ចការទាំងនេះ ត្រូវបានធ្វើឡើងដោយការថែរក្សា និងការពារព្រះធម៌ ឆ្លងតាមការរៀនសូត្រ និងរស់នៅជាមួយព្រះធម៌គ្រប់ពេលវេលាទាំងអស់ ។

## ៣. អនុវត្តន៍ :

❶ ចូរដឹកនាំឬក៏តែងតាំងនរណាម្នាក់ ឱ្យដឹកនាំការពិភាក្សាមួយ ស្តីពីការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ។ ជាពិសេស ចូរពិភាក្សាពីរបៀបបញ្ចសីល ឬសីលប្រាំ អរិយសច្ចៈទាំងបួន ព្រមទាំងអដ្ឋង្គិកមគ្គទាំងប្រាំបី ដើម្បីការត្រាស់ដឹង មានការជាប់ទាក់ទងគ្នាហើយនិងអះអាងបញ្ជាក់តម្លៃនៃបរិស្ថាន ។ ចូរសង្ខេបលទ្ធផលនៃការពិភាក្សា ដោយការសរសេរកំណត់ត្រាទុកជាឯកសារ រួចហើយយកទៅតំកល់ទុក នៅក្នុងបណ្ណាល័យ ឬមជ្ឈមណ្ឌលសិក្សាសំរាប់ជាឯកសារយោង ឬពិគ្រោះ ។ ចូរប្រកាសលទ្ធផលនៃការពិភាក្សានោះហើយនិងចែកជូនអត្ថបទ ដែលបានកត់ត្រាទុកនេះ នៅពេលសំដែងធម្មទេសនាម្តងៗ ។

❷ ចូរពិភាក្សាបញ្ញត្តិនៃឃ្លាថា : "**យាទិសំ វបតេ ពីជំ**
**តាទិសំ លភតេ ផលំ** "

ប្រែថា : *"បុគ្គលសាបព្រោះនូវពូជយ៉ាងណា*
*រមែងទទួលនូវផលយ៉ាងនោះ"* ។

❸ ចូរពិភាក្សាពីគំនិតដែលទាក់ទងគ្នា :

" បុញ្ញ បាប កម្ម ហេតុផល " និង " ចរិត្ត "

ប្រែថា : *"បុណ្យ បាប អំពើ ហេតុផល"* និង *"សុខបន្តិចបន្តួច"* ។

**គុណភាពបរិស្ថាន គឺជាតម្រូវការនៃមនុស្ស សត្វ និង រុក្ខជាតិ**

# ២. អត្ថន័យនៃពាក្យវត្ត

១. **វត្ថុបំណង** : ដើម្បីបង្ហាញឱ្យឃើញថា វត្តជាទីកន្លែងសក្ការៈមួយស្អាត មានសុខភាពល្អ និងមានសោភណភាព នៅក្នុងភាពចុះសម្រុងគ្នាជាមួយធាតុ ឬផ្នែកទាំងអស់នៃបរិស្ថាន (ធម្មជាតិ មនុស្ស និងសង្គម-វប្បធម៌) ។

២. **លំហាត់បង្រៀន** :

អ្វីខ្លះជាអត្ថន័យនៃពាក្យ **វត្ត** ? ហើយចុះអត្ថន័យពិតប្រាកដរបស់ពាក្យថា **វត្ត** គឺជាអ្វី ? ពិតហើយ ក្នុងភាសាខ្មែរពាក្យ **វត្ត** នេះមានន័យថា **ព្រះវិហារ** ឬ **វិហារ** ។ ប៉ុន្តែដើម្បីយល់នូវអត្ថន័យលាក់កំបាំងរបស់ពាក្យនេះ យើងត្រូវវិលត្រឡប់ទៅរកដើមកំណើតរបស់ពាក្យនោះឡើងវិញ ។

ពាក្យថា **វត្ត** គឺជាពាក្យក្លាយមកពីពាក្យបាលីថា **វត្ថុ** ដែលមានន័យថា *ប្រថពី ធរណី ទីធ្លា ឬកម្មសិទ្ធិមួយដុំ* ។ ពាក្យ **វត្ថុ** នេះ តែងតែយកទៅប្រើជារឿយៗក្នុងការភ្ជាប់ជាមួយនឹងស័ព្ទ **អារាម** ។ ដូច្នេះ **អារាម** នេះ បង្កើតបានជាពាក្យ **អារាមវត្ថុ** ដែលនៅក្នុងភាសាខ្មែរថា *វត្តអារាម* ដែរនោះ [១] ។

ពេលនេះ យើងគប្បីយល់ថាអ្វីទៅជា **អារាម** នោះ ។ ស័ព្ទបាលីនេះបង្កើតបានជារូបារម្មណ៍ គួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងចិត្តរបស់យើង ។ យោងតាមវចនានុក្រមបាលី

---

[១] *វត្ត ក្លាយមកពីពាក្យបាលីថា វត្តៈ (សំ. វតិៈ) ដែលមានន័យថា ការប្រព្រឹត្ត សេចក្តីប្រតិបត្តិ ឬ ការកាន់សីលធម៌ ។ ខ្មែរយើងបានប្រើពាក្យ វត្ត នេះ ដើម្បីសម្គាល់ "ទីដែលមានវត្តប្រតិបត្តិ" ឬ "អាវាស ឬអារាមជាទីអាស្រ័យរបស់ពួកសមណៈ" ។ ដើម្បីសម្រួលដល់ការនិយាយស្តី គេបានភ្ជាប់ពាក្យវត្ត ទៅនឹង អារាម (នេះជាការយល់ឃើញរបស់ឯកឧត្តម ឈន អៀម ដែលប្លែកពីសេចក្តីអធិប្បាយរបស់ព្រះតេជព្រះគុណ សោភិត ថេរោ ខាងលើ) ។*

អត្ថន័យជាអក្សរសាស្ត្រនៃ **អារាម** គឺ *សួនច្បារ ឬឧទ្យានកំសាន្ត* ។ ទីកន្លែងបែបនេះ សុទ្ធតែប្រកបដោយព្រៃឈើ ដែលបញ្ចេញផ្កា និងផ្លែបង្អួតគ្នា ហើយដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះភិក្ខុសង្ឃបានប្រើប្រាស់សំរាប់ពិភាក្សាគ្នា និងសំរាកលំហែកាយ ។

ចូរយើងក្រឡេកមើលឧទាហរណ៍ខ្លះៗ ដូចខាងក្រោមនេះ :

**វេឡុវន_អារាម** = *សួនកំសាន្តដែលសម្បូរដើមឫស្សី*

**អម្ពវន_អារាម** = *សួនកំសាន្តដែលសម្បូរដើមស្វាយ*

**និគ្រោធ_អារាម** = *សួនកំសាន្តដែលសម្បូរដើមជ្រៃ*

**ជេតវន_អារាម** = *សួនកំសាន្តដែលជាកម្មសិទ្ធិរបស់ព្រះអង្គម្ចាស់ **ជេត*** ។

សួនកំសាន្តជាច្រើនបែបនេះ នៅប្រទេសឥណ្ឌាបានត្រូវគេប្រគល់ថ្វាយដល់ព្រះពុទ្ធ និងសាវ័ករបស់ព្រះអង្គ ដែលនៅសម័យនោះ គេក៏បានប្រើប្រាស់ជាលំនៅឋានផងដែរ ។ ក្នុងន័យនេះ **អារាម** ឬ **វត្តអារាម** ក្លាយទៅជាវេវចនស័ព្ទសំរាប់ទីកន្លែង ដែលព្រះសង្ឃពុទ្ធសាសនិកស្នាក់អាស្រ័យនៅ ។

យើងក៏អាចសិក្សាស្រាវជ្រាវពាក្យក្រោយៗមកទៀតផងដែរ ដោយមានជំនួយពី **សេចក្តីអធិប្បាយវិន័យ** ឬ **អដ្ឋកថា** ដែលបានចែងយ៉ាងដូច្នេះថា :

" **អាគន្ត្វា រមតីតិ អារាមំ** "

ប្រែថា : *"កាលបើគេបានចូលទៅក្នុងហើយ គេមានសេចក្តីសប្បាយរីករាយ ទីនោះហើយដែលគេហៅថាអារាម"* ។

" **មនំ រមតីតិ អារាមំ** "

ដែលប្រែថា : *"កន្លែងណាដែលមានទីជុំវិញប្រកបដោយសេចក្តីសុខសប្បាយ គឺទីនោះហើយគេហៅថា អារាម"* ។

ដោយមានការបកស្រាយពាក្យ **អារាម** អស់ទាំងនេះ យើងអាចយល់បានថា **វត្ត** ឬ **អារាម** គឺជាទីកន្លែងស្ទើរតែមិនក្រៅពីលំនៅឋានរបស់ភិក្ខុសង្ឃនោះឯង ។ តាំងពីដើមទីមកម្ល៉េះ គេបានយល់ថា **វត្ត** ជាទីកន្លែង ប្រកបដោយម្លប់ត្រឈើងត្រឈៃ ស្អាតបាតប្រកបដោយបរិយាកាសសប្បាយក្រៃលែង ។ នៅពេលចូលវត្តអារាម ដែលបរិយាកាសជុំវិញមានសណ្តាប់ធ្នាប់ ស្អាតបាតល្អ និងមានសោភណភាពនោះ គេម្នាក់ៗនឹងជួបស្ថានភាពផ្លូវចិត្តមួយដែលភ្លឺស្វាង និងមានសុភមង្គលជាមិនខាន ។

ហេតុដូច្នេះហើយ **វត្ត** គឺជាលំនៅឋានរបស់ភិក្ខុទាំងឡាយ ។ ប៉ុន្តែថា *តើវត្តទាំងអស់អាចហៅថាអារាមពិតប្រាកដបានឬទេ ?* យើងគប្បីយល់ថា វត្តពិតប្រាកដគឺជាកន្លែងគំរូមួយនៃបរិស្ថានស្អាតល្អ ពោលគឺជាទីកន្លែងសក្ការៈមួយ មានសណ្តាប់ធ្នាប់ រៀបរយ និងស្អាតជាប់ជានិច្ច គួរឱ្យគយគន់ជាពន់ពេក ដែលនាំមកនូវសុខុមាលភាព ឱ្យដល់អ្នកស្នាក់អាស្រ័យនៅ ភ្ញៀវមកទស្សនា និងសព្វសត្វទាំងពួង។

BUDDHIST INSTITUTE LIBRARY

## ៣. អនុវត្តន៍ :

❶ ចូររៀបចំ ឬឱ្យនរណាម្នាក់ រៀបចំព្រះសង្ឃជាក្រុមតូចៗ ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌដើមឈើទាំងអស់ រុក្ខជាតិគ្រប់ប្រភេទ ដើមផ្កា និងសត្វដែលមាននៅក្នុងវត្ត ។ គេអាចពិគ្រោះយោបល់ជាមួយចាស់ទុំណា ដែលស្គាល់ច្បាស់លាស់នូវភពរុក្ខជាតិ និងភពសត្វដើម្បីជាជំនួយ ។ ចូរចាត់តាំងព្រះភិក្ខុអង្គណាម្នាក់ ឱ្យធ្វើការកត់ត្រាឈ្មោះ និងពន្យល់បញ្ជីសារពើភ័ណ្ឌនោះ ទុកជាប្រភពនៃឯកសារពិគ្រោះ សំរាប់តំកល់នៅបណ្ណាល័យ ឬមជ្ឈមណ្ឌលសិក្សា ។

❷ ព្រះភិក្ខុសង្ឃគប្បីផ្តល់បន្តនូវអ្វីដែលព្រះអង្គបានសិក្សារួចមកហើយ ក្នុងន័យ

គោរពស្រឡាញ់ធម្មជាតិយ៉ាងជ្រាលជ្រៅទៅឱ្យក្មេងវត្ត ឬកុមារា-កុមារីដទៃទៀត នៅក្នុង និងនៅជុំវិញវត្ត ។

## អភិវឌ្ឍន៍ត្រូវធានាបរិស្ថានល្អ

## ៣. ការចៀសវាងការបំពុល ឬ ភាពកខ្វក់តាមរយៈព្រះវិន័យ

**១. វត្ថុបំណង** : ដើម្បីឱ្យព្រះភិក្ខុសង្ឃទាំងឡាយយល់ថា បរិស្ថានមួយដែលពុល ឬ កខ្វក់នោះ គឺបណ្តាលមកពីការបំពុល ឬធ្វើឱ្យកខ្វក់ពីសំណាក់ផ្ទៃក្នុង ឬចិត្តខាងក្នុងតែម្តង ។

**២. លំនាំបង្រៀន** :

ថ្នាំជក់ មានផ្ទុកទៅដោយជាតិនីកូទីន ជាប្រភេទថ្នាំស្រវឹងម៉្យាងដែលធ្វើឱ្យញៀន ។ អ្នកជក់បារីភាគច្រើន មានការលំបាកជាខ្លាំងដើម្បីបន្ថយ ឬលះបង់ការជក់បារីនេះ ។ ជាតិនីកូទីន បង្កឱ្យកើតជំងឺមហារីកសួត និងគ្រោះថ្នាក់ផ្សេងៗទៀតដល់សុខភាព នៅក្នុងរាងកាយរបស់មនុស្សយើង ។ មានមនុស្សជិតមួយលាននាក់ ដែលបានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារតែជំងឺទាក់ទងនឹងការជក់បារី ។ ការជក់បារី វាមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់អ្នកជក់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងធ្វើឱ្យប៉ះពាល់ដល់សុខភាពកុមារ និងអ្នកដទៃទៀត ដែលនៅជិតនៅពេលដែលពួកគេដកដង្ហើមស្រូបយកផ្សែងបារី ។ ជាការជាក់ច្បាស់ណាស់ថា ការជក់បារីជារូបភាពមួយនៃការបំពុល ដែលធ្វើឱ្យពុល ឬកខ្វក់ដល់បរិស្ថាននៅជុំវិញខ្លួនយើង ។ ផ្សែងដែលមានសារធាតុគីមី ចេញពីគ្រប់យានយន្ត និងរោងចក្រទាំងឡាយ ក៏ធ្វើឱ្យកខ្វក់ ឬពុលដល់ខ្យល់អាកាស និងសួតរបស់មនុស្សយើងផងដែរ ។ រីឯការបំពុលដោយសូរសំឡេងចេញពីវីដេអូ និងចរាចរតាមដងផ្លូវ ឬវិថី ក៏ធ្វើឱ្យប៉ះពាល់ ឬរំខានចិត្តដល់អារម្មណ៍ស្ងប់ស្ងៀមរបស់មនុស្សម្នាក់ៗផងដែរ ។ ដីក៏ពុលដែរ ដោយសារតែសារធាតុគីមីចេញពីរោងឧស្សាហកម្ម និងការចោលសំរាម ឬសំណល់គ្រប់ប្រភេទពាសវាលពាសកាល ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានដាក់បញ្ញត្តច្បាប់វិន័យ ចំពោះព្រះភិក្ខុសង្ឃទាំងឡាយ សំរាប់ជាប្រយោជន៍ និងសុខុមាលភាពរបស់លោកទាំងនោះ ។ ព្រះភិក្ខុសង្ឃល្អ ដែលប្រព្រឹត្ត ស្របតាមលំអានព្រះវិន័យ ក៏បានប្រើប្រាស់ជាគំរូគេមួយ សំរាប់ការប្រព្រឹត្តល្អរបស់មនុស្ស ទាំងពួង ។ យោងតាមព្រះសម្មាសម្ពុទ្ធជាម្ចាស់ ការបណ្តុះបណ្តាលព្រះភិក្ខុសង្ឃ ឱ្យមានគំនិត មារយាទល្អសមរម្យ ដើម្បីរំងាប់ទុក្ខ ឬការឈឺចាប់ គឺជាតម្រូវការមួយយ៉ាងចាំបាច់ និងជា បន្ទាន់ កាលបើព្រះភិក្ខុសង្ឃត្រូវបានគេសន្មតថា ជាអ្នកដឹកនាំប្រៀនប្រដៅឱ្យដល់សង្គមគ្រហស្ថ ។ ដូច្នេះព្រះភិក្ខុសង្ឃ ត្រូវតែយកព្រះទ័យទុកដាក់អំពីការប្រព្រឹត្តរបស់ខ្លួន និងរបៀប របបរស់នៅរបស់ព្រះអង្គ ។ ព្រះភិក្ខុសង្ឃ ត្រូវបានគេសុំឱ្យលះបង់ទម្លាប់អាក្រក់ចេញ ដែល មានព្រះភិក្ខុអង្គខ្លះនៅតែឆាន់បារី ដោយពុំអាចលះបង់ ឬគ្រប់គ្រងផ្លូវចិត្តខ្លួនឯងបាន ។ ( ព្រះសម្មាសម្ពុទ្ធទ្រង់បានអនុញ្ញាតឱ្យភិក្ខុឆាន់បារីបាន លុះណាតែបារីនោះជាថ្នាំ ដើម្បី ព្យាបាលជំងឺ ) ។

អ្វីៗទាំងអស់ខាងលើនេះ មានន័យថា ការបំពុល ដែលយើងឃើញ នៅជុំវិញខ្លួន យើង វាជាលទ្ធផលនៃអវិជ្ជា បង្កដោយ **លោភៈ ទោសៈ** និង **មោហៈ** ដែលទាំងអស់នេះ មានកើតឡើង នៅក្នុងចិត្តគំនិតរបស់យើង ។ យើងអាចទទួលបាន ឬមានបរិស្ថានមួយល្អ មិនពុល ឬកខ្វក់ នៅពេលណា ដែលយើងមានលទ្ធភាពលាងជម្រះការបំពុល ឬភាពកខ្វក់ ឱ្យស្អាតស្រឡះ ចេញពីសន្តានចិត្តរបស់យើងឱ្យអស់ ។ ព្រះវិន័យសំរាប់ព្រះភិក្ខុសង្ឃ និង **បញ្ចសីល** ឬសិក្ខាបទទាំង៥ សំរាប់គ្រហស្ថ គឺជាច្បាប់ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង បានប្រទានដល់មនុស្សទាំងអស់ ដើម្បីជំនះរាល់ការបំពុលផ្ទៃក្នុងចិត្តរបស់យើង ។

សំរាប់យើងជាភិក្ខុ ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសដូច្នេះថា :

" **អត្តានមេវ បឋមំ បដិរូបេ និវេសយេ** "

ប្រែថា: *" គេត្រូវតែធ្វើខ្លួនឱ្យបានត្រឹមត្រូវ និងថែរក្សាឱ្យល្អប្រពៃជាមុនសិន មុនពេលទៅប្រៀនប្រដៅ ឬណែនាំទូន្មានអ្នកដទៃ "* ។

នៅក្នុងន័យនេះ យើងអាចយល់បានពីរបៀប ដែលការប្រព្រឹត្តល្អត្រឹមត្រូវរបស់ព្រះភិក្ខុសង្ឃស្របទៅតាមលំអានព្រះវិន័យ គឺធ្វើឡើងដើម្បីចៀសវាងការបំពុល និងលើកកំពស់កែលំអដល់បរិស្ថានទាំងមូល សំរាប់ទាំងអស់គ្នា ។

## ៣. អនុវត្តន៍ :

■ វិធីសាស្ត្រដ៏ល្អបំផុត ដើម្បីសំអាតឱ្យស្អាត ការបំពុលនៅផ្ទៃក្នុងចិត្តរបស់បុគ្គលម្នាក់ៗបាននោះ គឺដោយការប្រតិបត្តិតាំងសមាធិ ភាវនាធម៌នេះឯង ។ ចូរនិមន្ត ឬអញ្ជើញអ្នកជំនាញខាងសមាធិធម៌ ដើម្បីចាប់ផ្តើមកម្មវិធីតាំងសមាធិ សំរាប់ភិក្ខុទាំងឡាយ ដែលគង់នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ។

**ការពារបរិស្ថាន គឺការពារសុខភាពរបស់យើង**

## ៤. កិច្ចវត្តប្រចាំថ្ងៃរបស់ព្រះសង្ឃធ្វើឱ្យបរិស្ថានស្អាតបរិសុទ្ធ

**១. វត្ថុបំណង :** ដើម្បីបំពាក់បំប៉នវិន័យនៃការរក្សាកិច្ចវត្តប្រចាំថ្ងៃ ឱ្យបានជាប់លាប់ជាប្រចាំ ក្នុងបំណងពង្រឹងគុណភាពបរិស្ថាន ។

**២. លំនាំមេរៀន :**

ការខ្ជិលច្រអូស និងការចំណាយពេលចោលឥតប្រយោជន៍ នឹងនាំទៅរកបរិស្ថានមួយ ប្រកបដោយលក្ខណៈអវិជ្ជមាន និងពុំមានសុខភាពល្អ ។ នៅថ្ងៃពេញបូរមី ខែពិសាខ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ កំពុងរៀបចំដំណើរចុងក្រោយបង្អស់របស់ព្រះអង្គ ពោលគឺ **មហាបរិនិព្វាន** ។ ភិក្ខុជាសាវ័កជាច្រើនអនេក បានកើតទុក្ខយ៉ាងសោកសង្រេងក្រៀមក្រំ នៅជុំវិញព្រះបរមគ្រូជាទីស្រឡាញ់ ។ ដោយទ្រង់ទតឃើញភិក្ខុសង្ឃជាសាវ័កទាំងនោះ យំសោក ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានចាប់ផ្ដើមលួងចិត្តដល់ភិក្ខុទាំងឡាយនោះ ដោយព្រះទ័យមេត្តាករុណាធម៌ ដ៏ធំធេងអស្ចារ្យ និងទ្រង់មានព្រះពុទ្ធដីកាយ៉ាងដូច្នេះថា :

*"ម្នាលភិក្ខុជាសាវ័កទាំងឡាយអើយ ចូរកុំព្រួយបារម្ភអ្វីឱ្យសោះ វត្ថុគ្រប់យ៉ាងរមែងតែត្រូវប្រែប្រួលផ្លាស់ប្ដូរជានិច្ច ព្រោះហេតុនេះហើយ ចូរខិតខំធ្វើការឱ្យបានខ្លាំងក្លានិងឆាប់រហ័ស ។ ចូរកុំខ្ជះខ្ជាយពេលវេលាឱ្យកន្លងផុតទៅ ដោយពុំបានធ្វើអ្វីសោះ"* [២] ។

អាស្រ័យហេតុនេះ គ្មានពេលវេលាណាមួយ ដែលត្រូវខ្ជះខ្ជាយឬបង្ហាតពេលវេលាឡើយ ។ ពេលវេលា គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃ ដែលយើងគប្បីប្រើប្រាស់ឱ្យបានយ៉ាងល្អប្រពៃ ដោយមានផែនការល្អត្រឹមត្រូវ ។ ឧទាហរណ៍ ដ៏ល្បីល្បាញជាងគេ នៅក្នុងប្រវត្តិ

---

[២] ***អប្បមាទេន សម្បាទេថ*** *មហាបរិនិព្វានសូត្រ ទីឃនិកាយ ។*

នៃការប្រើប្រាស់ពេលវេលាយ៉ាងសុក្រឹតនោះ ក៏ត្រូវបានព្រះសម្មាសម្ពុទ្ធជាអម្ចាស់ផ្តល់ឱ្យផង ដែរ ។ យោងតាមទម្លាប់ប្រចាំថ្ងៃរបស់ព្រះអង្គ ទ្រង់មានកាលវិភាគមួយច្បាស់លាស់ និង តែងតែដៅបញ្ជាក់ដូច្នេះថា : " **កាលំមញ្ញថ** " [៣]

មានន័យថា: *" ចូរអ្នកប្រើពេលវេលាឱ្យបានត្រឹមត្រូវ ឬ*
*អ្នកត្រូវតែដឹងពេលវេលាផ្ទាល់ខ្លួនរបស់អ្នក*
*(ភាពជាបុគ្គលអ្នកស្គាល់នូវកាល) "* ។

យោងតាមកាលវិភាគប្រចាំថ្ងៃរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គបានបែងចែក ពុទ្ធកិច្ចប្រចាំថ្ងៃរបស់ព្រះអង្គជា ៥ ពេល ក្នុងមួយថ្ងៃ ដូចតទៅ :

*១. ពេលព្រឹក ( ប្រមាណពីម៉ោង ៦ ព្រឹក ទៅដល់ម៉ោង ១២ ថ្ងៃត្រង់ ) ។*

*២. ពេលរសៀល ( ប្រមាណពីម៉ោង ១២ ថ្ងៃត្រង់ ទៅដល់ម៉ោង ៦ ល្ងាច ) ។*

*៣. យាមទី ១ ឬបឋមយាម ( ប្រមាណពីម៉ោង ៦ ល្ងាច ទៅដល់ម៉ោង ១២ អធ្រាត្រ ) ។*

*៤. យាមទី ២ ឬមជ្ឈិមយាម ( ប្រមាណពីម៉ោង ១២ អធ្រាត្រ ទៅដល់ម៉ោង ២ ទៀបភ្លឺ ) ។*

*៥. យាមទី ៣ ឬ បច្ឆិមយាម ( ប្រមាណពីម៉ោង ២ ទៀបភ្លឺ ទៅដល់ម៉ោង ៦ ព្រឹក )* [៤] ។

តាមគន្លងនេះ ព្រះសម្មាសម្ពុទ្ធបានរៀបចំផែនការ ទៅតាមពេលវេលានិមួយៗ ជា រៀងរាល់ថ្ងៃ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់រំពឹងថា ព្រះភិក្ខុសង្ឃជាសាវ័ករបស់ព្រះអង្គ នឹងអនុវត្ត

---

[3] *ជាធម្មតា ព្រះពុទ្ធអង្គទ្រង់បាននិក្ការអនុញ្ញាតឱ្យលាព្រះអង្គ ក្រោយការពិភាក្សា ។ អាគលោតិយា និងព្រះសូត្រទាំងឡាយដទៃ ជាច្រើនទៅក្នុងព្រះសុត្តន្តបិដក ។*

[៤] *មហាវគ្គ ធាតុ-និទ្ទេសកថា ៖ ១. បុព្វណ្ហ ២. អបរណ្ហ ៣. បុរិមយាម ៤. មជ្ឈិមយាម ៥. បច្ឆិមយាម ៖*

តាមផែនការរបស់ព្រះអង្គ ។

ដូច្នេះហើយ កិច្ចវត្តប្រចាំថ្ងៃ ឬតារាងកាលវិភាគ បានត្រូវព្រះមហាថេរទាំងឡាយពីមុនៗមក បង្កើតឡើងជាពិសេសសំរាប់យុវភិក្ខុទាំងឡាយ ។ តាមកិច្ចវត្តប្រចាំថ្ងៃនេះ មួយទិវា ឬមួយថ្ងៃរបស់ភិក្ខុ ចាប់ផ្តើមឡើងនៅមុនពេលព្រឹកព្រលឹមស្រាងៗ ។ ជាដំបូង ព្រះភិក្ខុត្រូវសំអាតខ្លួនប្រាណជាមុនសិន ។ បន្ទាប់មក សំអាតគ្រែនិងកុដិ ។ រួចមកទៀត សំអាតបរិស្ថាននៅជុំវិញព្រះវិហារ ។ រីឯមុខកុដិ ទីធ្លា សួនច្បារ ទីធ្វើសក្ការបូជា សាលាឆាន់។ល។ ក៏ត្រូវបោសសំអាតឱ្យបានស្អាតផងដែរ ។ ការស្រោចទឹករុក្ខជាតិ ការថែទាំផ្កា ឬផើងផ្កា និងការរៀបចំបរិវេណជុំវិញ ក៏ជាផ្នែកមួយផងដែរនៃដំណើរការនេះ ។ នេះគឺជាក្បួនខ្នាត និងជាកាតព្វកិច្ចរបស់ភិក្ខុ ដែលបង្ហាញឱ្យឃើញមុនគេ នៅក្នុងជីវភាពជាទំលាប់ប្រចាំថ្ងៃរបស់ភិក្ខុអង្គនីមួយៗ ។

បន្ទាប់មក ព្រះភិក្ខុសង្ឃអាចចែករំលែកពេលវេលារបស់ព្រះអង្គ ដោយការបិណ្ឌ-បាត ការសង្វាតរៀនសូត្រ ការសូត្រធម៌ ការសំដែងធម៌ទេសនា និងកាតព្វកិច្ចដទៃផ្សេងៗទៀត រហូតដល់ពេលចុងក្រោយបំផុតនៃថ្ងៃនីមួយៗ ។ នេះអាចប្រហែលជានៅម៉ោង ៥ ល្ងាច នៅពេលដែលភិក្ខុទាំងឡាយត្រូវបំពេញកាតព្វកិច្ចជាថ្មីម្តងទៀត ដោយការសំអាតខ្លួនប្រាណ និងបរិស្ថាននៅជុំវិញ តាមរបៀបដូចគ្នាទៅនឹងការប្រតិបត្តិ នៅក្នុងវេលាព្រឹកព្រលឹមដូច្នោះដែរ ។

ដូច្នេះ ព្រះភិក្ខុទាំងឡាយ ត្រូវតែសំអាតខ្លួនប្រាណ និងបរិស្ថានជុំវិញចំនួនពីរដងក្នុងមួយថ្ងៃ គឺនៅពេលព្រឹកព្រលឹម និងពេលព្រលប់ ។ ជាមួយនឹងសកម្មភាពនេះ ព្រះភិក្ខុមួយអង្គៗ អាចសំរេចបាននូវលទ្ធផលភ្លាមៗមួយចំនួន មានដូចជា :

១. ការហាត់ប្រាណដើម្បីសុខភាពល្អ ។

២. ការកែលំអ ឬសិរិតសំរាំងបញ្ញាស្មារតី តាមរយៈនៃការធ្វើភាវនាចិត្តទៅលើតែការងារល្អត្រឹមត្រូវ ។

៣. ការសំអាតទីឋាននៅជុំវិញដើម្បីលើកតំកើងជីវភាពប្រកបដោយសុខភាពល្អ ។

៤. ទាំងអ្នកស្រុកចំណុះជើងវត្ត ទាំងភ្ញៀវ មានសេចក្ដីសប្បាយរីករាយសាទរដោយបានឃើញបរិស្ថានល្អស្អាតបាត ។

៥. ការប្រៀនប្រដៅ ឬបង្រៀនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន តាមរយៈការបង្ហាញជាគំរូល្អៗឱ្យដល់ពួកគេ ។

នៅក្នុង **វិន័យបិដក** កាតព្វកិច្ចទាំងនេះ ត្រូវគេចាត់ទុកជា វត្តប្រតិបត្តិ ឬ កិច្ចវត្ត របស់ព្រះភិក្ខុរាល់អង្គជាប្រចាំថ្ងៃ ដូចដែល **អដ្ឋកថាវិន័យ** ថែងដូច្នេះថា :

**" វត្តំ ន បរិបូរេន្តោ ន សីលំ បរិបូរតិ "** [៥]

ប្រែថា : *"ប្រសិនបើភិក្ខុអង្គណាមួយមិនបានបំពេញនូវកាតព្វកិច្ចទាំងនេះទេ ភិក្ខុអង្គនោះនឹងមានឈ្មោះថា មិនរក្សានូវសីលសិក្ខាបទរបស់ខ្លួនបានល្អត្រឹមត្រូវឡើយ "* ។

សរុបសេចក្ដីមក ដើម្បីចៀសវាងការពុល ឬកករល្អក់ដល់សតិបញ្ញានោះ វិធីដ៏ប្រសើរជាងគេ ដើម្បីគោរពព្រះវិន័យក្នុងជីវភាពប្រចាំថ្ងៃ គឺតាមរយៈកិច្ចវត្តប្រចាំថ្ងៃ និងការធ្វើសមាធិតែប៉ុណ្ណោះ ។ ទាំងអស់នេះនឹងកាត់បន្ថយនូវលោភៈ ទោសៈ និងមោហៈ ដែលជាប្រភពនៃការពុល ឬការរេចរឹលបរិស្ថាននៅជុំវិញខ្លួនយើង ។

---

[៥] *សមន្តបាសាទិកា-វិនយអដ្ឋកថា វត្តក្ខន្ធក វណ្ណនា ដោយព្រះតេជព្រះគុណ ព្រះពុទ្ធឃោសៈ ។*

## ៣. អនុវត្តន៍ :

- ចូរធ្វើការកែលំអ ឬបញ្ចូលកម្មវិធីកិច្ចវត្តប្រចាំថ្ងៃ នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ។

**ចូររក្សាបរិស្ថាន ដើម្បីជីវិតស្ថិតស្ថេរគង់វង្ស**

# ៥. ការបង្រៀនបរិស្ថានតាមរយៈព្រះភិក្ខុសង្ឃ

**១. វត្ថុបំណង** : ដើម្បីបង្រៀនដល់ភិក្ខុទាំងឡាយ ឱ្យចេះណែនាំឧបាសក-ឧបាសិកាទាំងអស់ ក្នុងការអភិវឌ្ឍពីទំនាក់ទំនងរវាងការប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនា និងបរិស្ថានស្អាតបរិសុទ្ធ ។

**២. វិធីបង្រៀន** :

អស់រយៈពេលមិនជាយូរប៉ុន្មានទេ យើងទាំងអស់គ្នាធ្លាប់បានឮពីផ្ទាំងទឹកកកដ៏ធំសំបើមមួយ មានបណ្តោយប្រមាណជាង ៨ គីឡូម៉ែត ស្រុតរលំ ហើយបាក់ធ្លាក់ចូលទៅក្នុងសមុទ្រ នៅក្បែរប៉ូលខាងជើង ។ មានអ្នកប្រាជ្ញវិទ្យាសាស្ត្រជាច្រើន បានអះអាងថា ការរលាយដុំទឹកកកបាក់ធ្លាក់មកយ៉ាងដូច្នេះ គឺបណ្តាលមកពីការឡើងកំដៅរបស់ផែនដី បង្កឡើងមួយចំណែកដោយសារតែការកាប់បំផ្លាញព្រៃឈើ ។ បាតុភូតនៃការរលាយទឹកកកនេះនឹងធ្វើឱ្យកំពស់ទឹកសមុទ្រកើនឡើង ហើយមុខតែគំរាមកំហែងដល់កោះទាបៗ និងតំបន់ឆ្នេរសមុទ្រផងដែរ ។ ប្រទេសកម្ពុជា មានឆ្នេរសមុទ្រប្រវែងប្រមាណ ៤៤៣ គីឡូម៉ែត ។ បញ្ហាបរិស្ថាន មួយផ្សេងទៀត គឺការធ្លុះធ្លាយស្រទាប់អូសូន (ozone) ដែលបានការពារផែនដីពីកាំរស្មីស្វាយអ៊ុលត្រាដ៏កាចសាហាវ ដែលអាចបង្កឱ្យមានរោគមហារីកស្បែក និងជំងឺដទៃទៀត ។ ស្រទាប់អូសូននេះ កំពុងទទួលការបំផ្លាញ ដោយការបញ្ចេញជាតិគីមីពីរោងចក្រឧស្សាហកម្មធំៗ ចូលទៅក្នុងបរិយាកាស ។ តាមរយៈរូបភាពរបស់ផ្កាយរណបដែលទទួលបាននាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញថា ប្រហោងធ្លុះធ្លាយនៃស្រទាប់អូសូននេះមានទំហំប្រមាណជិតពីរដង នៃផ្ទៃដីសហរដ្ឋអាមេរិកទាំងមូល ។

ឧប្បត្តិហេតុទាំងនេះ និងហេតុការណ៍ដទៃទៀតជាច្រើន កំពុងតែចង្អុលបង្ហាញទៅរកគ្រោះមហន្តរាយរបស់ពិភពលោកទាំងមូល ។ ជាការជាក់ច្បាស់ណាស់ថា និទានការនៃគ្រោះថ្នាក់នេះ គឺបណ្តាលមកពីអំពើប្រកបដោយ លោភៈ ទោសៈ និងមោហៈរបស់មនុស្ស ។ សង្គមកម្ពុជា ក៏កំពុងប្រឈមមុខនឹងបញ្ហាបរិស្ថានផ្សេងៗដែរ មានដូចជា កន្លែងចាក់ចោលសំណល់មិនគ្រប់គ្រាន់ ការទាញយកផលពីធនធានធម្មជាតិដែលមិនធានាបាននូវនិរន្តរភាព ការបំពុល និងបញ្ហាផ្សេងៗទៀត ។

កាតព្វកិច្ចដ៏ចម្បងបង្អស់របស់ព្រះភិក្ខុសង្ឃ គឺត្រូវបង្ហាត់បង្រៀនព្រះធម៌ឱ្យដល់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យពួកគេម្នាក់ៗមានលទ្ធភាពប្រព្រឹត្តតាមមាគ៌ាកណ្តាល ឬមជ្ឈិម-បដិបទា ។ ទាក់ទងទៅនឹងការពន្យល់ពីសេវាកម្មរបស់ភិក្ខុសង្ឃ ចំពោះគ្រហស្ថដែលបូជាខ្លួននោះ នាសម័យថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធ ទ្រង់មានពុទ្ធដីកាយ៉ាងដូច្នេះថា :

**" បាបា និវារេន្តិ កល្យាណេ និវេសេន្តិ អស្សុតំ សាវេន្តិ**
**សុតំ បរិយោទបេន្តិ សគ្គស្ស មគ្គំ អាចិក្ខន្តិ ..... "**

ប្រែថា : *" ព្រះពុទ្ធទាំងឡាយ ទ្រង់សំដែងប្រាប់នូវផ្លូវនៃសួគ៌*
*ដោយហាមមិនឱ្យធ្វើអំពើអាក្រក់ ឱ្យធ្វើតែអំពើល្អ*
*ញ៉ាំងកិរិយាស្តាប់មិនទាន់ច្បាស់ ឱ្យច្បាស់ឡើង*
*ញ៉ាំងកិរិយាស្តាប់ច្បាស់ហើយ ឱ្យរឹតតែច្បាស់ឡើង " ។*

តាមប្រវត្តិសាស្ត្រប្រទេសកម្ពុជាយើង ក៏ដូចបណ្តាប្រទេសជិតខាង ដែលកាន់ព្រះពុទ្ធសាសនាថេរវាទដូចយើងដែរ កាតព្វកិច្ចនេះត្រូវប្រតិបត្តិឡើងដោយព្រះសង្ឃ ឬក៏សហ-គមន៍ព្រះសង្ឃតែម្តង ។ ថ្វីបើរចនាសម្ពន្ធសង្គមត្រូវគេរុះរើ ឬរំលាយចោល នៅក្នុងប៉ុន្មានទសវត្សថ្មីៗកន្លងទៅនេះ ដោយសារតែទំនាស់ផ្នែកនយោបាយក៏ដោយ ប៉ុន្តែព្រះសង្ឃនៅតែ

អាចបន្តកាតព្វកិច្ចជាប្រវត្តិសាស្ត្រតាំងពីដើមទីមកម្ល៉េះ និងការជួយស្តារបរិស្ថានមនុស្សនៅក្នុងប្រទេសឱ្យបានល្អប្រសើរឡើងវិញ ដែលជាមាគ៌ាមួយ សំរាប់ជួសជុលបរិស្ថានសង្គមវប្បធម៌ និងបរិស្ថានធម្មជាតិ ។

ព្រះសង្ឃពុទ្ធសាសនិក គឺជាក្រុម ឬអង្គការសាសនាស្ម័គ្រចិត្តមួយដំបូងគេហើយ ដែលមានការរៀបចំបានច្បាស់លាស់នៅក្នុងពិភពលោកនេះ ។ គឺនៅរវាងសតវត្សទី ៦ មុនគ្រឹស្តសករាជ ដែលព្រះសម្មាសម្ពុទ្ធ បានលើកទឹកចិត្តដល់សាវ័ករបស់ព្រះអង្គ ដោយមានពុទ្ធដីកាយ៉ាងដូច្នេះថា :

**" ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ "**

ប្រែថា : " *ម្នាលភិក្ខុទាំងឡាយ ចូរអ្នកប្រព្រឹត្តនិងប្រតិបត្តិ*
*ដើម្បីជាប្រយោជន៍ដល់ជនជាច្រើន និងដើម្បី*
*សេចក្តីសុខដល់ជនជាច្រើនដោយមេត្តាករុណា*
*ចំពោះសត្វលោកទាំងអស់លើពិភពលោក* " ។

ដោយប្រកាន់យកនូវស្មារតីនៃការណែនាំទូន្មានទាំងនេះ យើងអាចសំរេចចិត្តចំពោះកាតព្វកិច្ចថា តើភិក្ខុសង្ឃគប្បីធ្វើអ្វីខ្លះ នៅក្នុងសង្គមបច្ចុប្បន្ននេះ ។ នៅក្នុងដំណាក់កាលនេះ ជាការពិតណាស់ហើយ ដែលភិក្ខុទាំងឡាយ អាចជួយសង្គ្រោះបរិស្ថានយ៉ាងសម្បើម នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះ ឱ្យផុតពីមហន្តរាយនានាកំពុងមកដល់ ដោយការជួយសំអាតជំងឺខាងផ្លូវចិត្តរបស់ប្រជាពលរដ្ឋ តាមរយៈព្រះធម៌ ឬមជ្ឈិមបដិបទា ។

កាតព្វកិច្ចនេះ អាចអនុវត្តតាមការប្រៀនប្រដៅធម៌ទេសនា និងលើកទឹកចិត្តមនុស្សទូទៅ ឱ្យប្រតិបត្តិតាមគន្លងសីលធម៌ ដែលមួយផ្នែក ដោយការសំអាតបរិស្ថាននៅជុំវិញពួកគេ ។ ជាឧទាហរណ៍ ដូចជា សីលប្រាំ ឬបញ្ចសីលជាដើម អាចត្រូវតែប្រតិបត្តិ

ប្រកបដោយសតិសម្បជញ្ញៈជាប្រចាំថ្ងៃ ។ នៅក្នុងការគោរពប្រតិបត្តិតាមបញ្ចសីលនេះ មនុស្សម្នាក់ៗ អាចទទួលបាននូវមេត្តាធម៌ និងសប្បុរសធម៌ ហើយដែលតាមមធ្យោបាយនោះ ទើបគេអភិវឌ្ឍបាននូវបរិស្ថានដ៏ប្រសើរមួយ ទោះជាបរិស្ថានធម្មជាតិ មនុស្ស និងសង្គម-វប្បធម៌ក៏ដោយ ។

## ៣. អនុវត្តន៍ :

❶ ចូររៀបចំភិក្ខុសង្ឃ ឬសិស្សគណរបស់ព្រះតេជព្រះគុណ-លោកអ្នក ដើម្បីសិក្សារៀនសូត្រអត្ថបទសិក្សាមួយ ដែលមានចំណងជើងថា **សម្រែកព្រៃឈើ** ដើម្បីឱ្យភិក្ខុទាំងឡាយ អាចចូលរួមក្នុងការបង្រៀនអត្ថបទនេះ ឱ្យដល់ឧបាសក-ឧបាសិកាទាំងអស់ផងដែរ ។

❷ ចូររៀបចំធម្មទេសនាស្តីអំពីព្រះធម៌ និងបរិស្ថាន ដែលចាត់ទុកជាវិធីមួយ ដើម្បីលើកទឹកចិត្តឱ្យដល់ឧបាសក-ឧបាសិកា បានចូលរួមសិក្សា **សម្រែកព្រៃឈើ** នេះ។

**បរិស្ថានខណៈនេះ គឺជាអនាគតរបស់អ្នក**

# ផ្នែកទី២

# ការអប់រំបរិស្ថាន

# សំរាប់ដូនជី និង តាជី

## មេរៀនទី ១ : ការអភិវឌ្ឍ និងសារប្រយោជន៍ នៃមជ្ឈមណ្ឌលសហគមន៍វត្តសិក្សាធម៌

# ការអភិវឌ្ឍ និងសារប្រយោជន៍នៃមជ្ឈមណ្ឌលសហគមន៍វត្ត សិក្សាព្រះធម៌

## ១. សេចក្ដីផ្ដើម :

គណៈរបស់ភិក្ខុនីសង្ឃ ជាបង្គោលបង្អែកមួយ នៅក្នុងចំណោមបង្គោលបង្អែកទាំងបួន ដែលបានទ្រទ្រង់ព្រះពុទ្ធសាសនា ដ៏ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ តាំងពីព្រេងនាយមកម្ល៉េះ ។ ចាប់តាំងពីគណៈសង្ឃនេះបានផុតរលត់ទៅ ភិក្ខុនីទាំងឡាយនៅប្រទេសកម្ពុជា ត្រូវបានតំណាងដោយ " **ដូនជី ឬ តាជី** " ជាគ្រហស្ថ ដែលប្រព្រឹត្តកាន់តាមសិក្ខាបទប្រាំបី ឬសិក្ខាបទដប់ ។ ស្ត្រីដ៏មានភាពចាស់ទុំ និងពោរពេញទៅដោយភាពស្មោះត្រង់ទាំងនេះ មានសារប្រយោជន៍យ៉ាងសំបើម នៅក្នុងការទ្រទ្រង់សកម្មភាពទាំងឡាយរបស់វត្ត ។ ស្ត្រីទាំងឡាយ ដែលបានបំពេញភារកិច្ចជាមេផ្ទះ ឬគេហបាល ច្រើនតែចូលទៅនៅវត្ត ដើម្បីប្រតិបត្តិសាសនានៅក្នុងចុងជីវិតរបស់ខ្លួន ដូនជីភាគច្រើននៅប្រទេសកម្ពុជាច្រើនតែស្ថិតក្នុងវ័យជាង ៦០ ឆ្នាំ ។ ដូនជីខ្លះទៀត ភាគច្រើនជាស្ត្រីមេម៉ាយ ស្ថិតក្នុងវ័យកណ្ដាល ឬជាយុវវ័យនៅឡើយ ។ នៅតាមវត្តជាច្រើនទៀតនាបច្ចុប្បន្ននេះ ពួកគេរមែងតែចេញចូលវត្ត ដើម្បីទទួលរ៉ាប់រងការងាររបស់វត្ត មានដូចជា ការចំអិនអាហារ ការបោសសំអាត ការសូត្រធម៌ និងការធ្វើសមាធិភាវនាធម៌ជាដើម ។

## ២. ក្រុមសិក្សាព្រះធម៌ :

សេចក្ដីត្រូវការមួយដែលដូនជីជាច្រើន បានសំដែងឱ្យឃើញនោះ គឺការសិក្សាព្រះធម៌ ។ ប្រសិនបើព្រះតេជព្រះគុណជាចៅអធិការវត្ត ឬជាមេដឹកនាំភិក្ខុសង្ឃ ពុំទាន់បាន

រៀបចំក្រុមសិក្សាព្រះធមិនេះនៅឡើយទេ ដូច្នេះវាជាឱកាសល្អចាំបាច់សំរាប់ដូនជីផង និង វត្តផង ដើម្បីរៀបចំក្រុមសិក្សាព្រះធមិ ឱ្យមានដំណើរការឡើង ។ ព្រះអង្គអាចតែងតាំង ដូនជីណាម្នាក់ ដែលមានសមត្ថភាពពេញលេញ ក្នុងចំណោមដូនជីទាំងអស់ ដើម្បីដឹកនាំ ក្រុមសិក្សានេះ ក្រោមការគ្រប់គ្រងរបស់ព្រះអង្គផ្ទាល់តែម្តង ។ ព្រះអង្គអាចផ្តល់សៀវភៅ ធមិ ឱ្យដូនជីសំរាប់អាន និងពិភាក្សាគ្នា ហើយព្រះអង្គក៏អាចដឹកនាំ ពេលរៀនសូធ្យនេះម្តង ម្កាលផងដែរ ។

ដូនជីទាំងអស់ គប្បីមានលទ្ធភាពរៀនសូត្រ **គម្ពីរ សាស្ត្រា** ជាច្រើនមុខ ដែល មានជាប់ពាក់ព័ន្ធ និងមានប្រយោជន៍ចំពោះជីវភាពរស់នៅជាគ្រហស្ថ ។ **សិង្គាលោវាទ-សូត្រ** បានផ្តល់ឱវាទ អំពីវិធីថែរក្សាចំណងមិត្តភាព ប្រកបទៅដោយភាពស្និទ្ធស្នាល និង ភាពចុះសំរុងគ្នា រវាងសមាជិកទាំងឡាយក្នុងសង្គម ។ **បរាភវសូត្រ** បានលើកពន្យល់ពី របៀបដែលបុគ្គលធ្លាក់ខ្លួនចុះក្រីក្រ និងគ្មានសុភមង្គល ហើយនិងវិធីជៀសវាង ឬតស៊ូយក ជ័យជំនះលើរឿងអាក្រក់អស់ទាំងនោះ ។ **វសលសូត្រ** បានលើកបង្ហាញ និងពន្យល់ពី របៀបដែលបុគ្គលម្នាក់ៗ ក្លាយទៅជាបុគ្គល ដែលគួរឱ្យគោរព ប្រកបដោយភាពថ្លៃថ្នូរទៀត ផង តាមរយៈការប្រព្រឹត្តខ្លួន ឱ្យបានសមរម្យត្រឹមត្រូវល្អ ។ មាគ៌ាដ៏ត្រឹមត្រូវក្នុងការរក ប្រាក់ចំណូល ការចំណាយ និងការសន្សំប្រាក់ សុទ្ធតែមានការប្រៀនប្រដៅស្រាប់ នៅក្នុង ព្រះសូត្រមួយឈ្មោះ **ទីឃជាណុសូត្រ** ។

ជីវភាពគ្រួសារ ឬជីវភាពសាសនាដ៏មានសុភមង្គល និងមានភក្តីភាពនោះ នឹងជះ ពន្លឺដ៏ចិញ្ចែងចិញ្ចាចដល់បរិស្ថានសង្គម-វប្បធមិ ជាមិនខាន ។ ព្រះធមិប្រើសំរាប់ជាឃ្លាំង ទ្រព្យមួយសំរាប់គោលបំណងនេះ ។ ចំណេះដឹង និងការប្រតិបត្តិបែបដូចនេះ នឹងជួយដូនជី ទាំងនោះ ឱ្យចេះរកផ្លូវដឹកនាំសហគមន៍ទាំងឡាយ ដែលចំណុះឱ្យវត្តនីមួយៗ ។

## ៣. ព្រះធម៌ និង បរិស្ថាន :

បន្ទាប់ពីពេលវេលាខ្លះបានកន្លងទៅ ព្រះតេជព្រះគុណអាចបញ្ចូលប្រធានបទផ្សេងៗទៀត ដូចជាព្រះធម៌ និងបរិស្ថានទៅក្នុងក្រុមនេះ ។ ព្រះតេជព្រះគុណ ឬអាចារ្យដែលជាគ្រូឧទ្ទេស ទោះជាព្រះសង្ឃ ឬជាគ្រហស្ថក៏ដោយ ដែលព្រះអង្គបានតែងតាំងនោះ អាចដឹកនាំក្រុមនេះ ឱ្យសិក្សាស្រាវជ្រាវអំពីអត្ថបទស្វែងយល់របស់សហគមន៍ ដែលមានចំណងជើងថា " **សម្រែកព្រៃឈើ** "។ នៅដំណាក់កាលក្រោយៗមកទៀត នៅក្នុងការអភិវឌ្ឍក្រុមសិក្សាព្រះធម៌នេះ ដូនជីមួយចំនួនអាចចាប់ផ្តើមឈានចូលទៅក្នុងសហគមន៍ ។ ពេលនោះហើយ ដូនជីទាំងនោះ ដែលមានថាមពលរឹងមាំ និងមានទំនោរចិត្តវេទៅរកផងនោះ អាចចូលរួមចំណែកក្នុងការជួយលើកកំពស់ និងកែលំអគុណភាពនៃការរស់នៅក្នុងសហគមន៍ ។ ស្ត្រី និងកុមារ ជាពិសេសស្ត្រីមេផ្ទះ អាចទទួលបាននូវសារប្រយោជន៍ពីមេត្តាករុណាធម៌ និងការស្រឡាញ់ ប្រកបដោយសប្បុរសធម៌ ពីសំណាក់ដូនជីផងដែរ ។ សកម្មភាព ឬគំរោងការណាមួយ ដែលក្រុមសិក្សាព្រះធម៌អាចទទួលរ៉ាប់រងបាននោះ គឺការងារសិក្សាអប់រំថ្នាក់មត្តេយ្យសាលា របស់សហគមន៍នៅតាមវត្តនីមួយៗ ។

## ៤. សកម្មភាពសំរាប់កែលំអបរិស្ថានឱ្យបានស្អាត : *មត្តេយ្យសាលាសហគមន៍*

ដើម្បីបង្កើតបរិស្ថានមួយ ឱ្យបានស្អាតល្អនៅក្នុងសង្គមមនុស្ស ការសិក្សាអប់រំមានតួនាទីយ៉ាងសំខាន់បំផុត ។ ការសិក្សាអប់រំគួរតែចាប់ផ្តើម ពីដំណាក់ដើមដំបូងនៃកុមារភាព ។ នៅប្រទេសកម្ពុជា ដែលការសិក្សាអប់រំក្នុងកំរិតមត្តេយ្យសាលា មិនសូវមានជាទូទៅនោះ វត្តអាចមានតួនាទីយ៉ាងសំខាន់បំផុត ក្នុងការត្រៀមរៀបចំកុមារទាំងអស់ ឱ្យទទួលបានជោគជ័យទាំងនៅក្នុងសាលារៀន ទាំងនៅក្នុងផ្ទះសំបែងផងដែរ ។

ផលប្រយោជន៍ ពីកម្មវិធីមត្តេយ្យសាលានៅក្នុងវត្ត ដែលរៀបចំចាត់ចែងឡើង ដោយដូនជី ជាសមាជិករបស់ក្រុមសិក្សាព្រះធម៌នោះ មានច្រើនយ៉ាងណាស់ ។ វាអាច អនុញ្ញាតឱ្យម្តាយ ជាពិសេសស្ត្រីមេផ្ទះ មានពេលវេលាដ៏មានតម្លៃរបស់ខ្លួន ដើម្បីអាច ប្រកបការងារទទួលផល ឬអាចសិក្សារៀនសូត្របន្ថែមនូវជំនាញថ្មីៗទៀត ដោយរាប់ទាំងការចេះ អាន និងសរសេរទៀតផង ។ ចំណែកឯកុមារវិញ អាចទទួលបានផលប្រយោជន៍ច្រើនពីចិត្ត សប្បុរសធម៌ មេត្តាធម៌ គតិបណ្ឌិតល្អៗ ពីសំណាក់ដូនជីចាស់ៗ និងបានសិក្សាពីទំនាក់ទំនង ទៅវិញទៅមក ជាមួយកុមារដទៃទៀត ក្រោមកិច្ចគាំពារ ថែរក្សារបស់វត្តអារាមរបស់ ព្រះអង្គ ។ ដោយសារតែគេអាចរកបាននូវទីធ្លានៅក្នុងវត្ត និងការបូជាដោយស្ម័គ្រចិត្ត ពី សំណាក់ដូនជីទៀតនោះ ជាគោលការណ៍ រាល់សេវាកម្មទាំងនេះពុំចាំបាច់តម្រូវ ឬទាមទារ ប្រាក់កាសពីមាតាបិតាសិស្សសោះឡើយ ។ វាមិនតម្រូវឱ្យមានការរៀបចំម្ហូបអាហារឱ្យ ដល់កុមារឡើយ នៅពេលដែលកុមារមករៀន បានស្រស់ស្រូបអាហារពេលព្រឹករួចហើយ និងត្រូវត្រឡប់ទៅផ្ទះវិញ ដើម្បីស្រស់ស្រូបអាហារថ្ងៃត្រង់ ។ ក៏ប៉ុន្តែគេអាចលើកទឹកចិត្ត មាតាបិតាសិស្ស ដើម្បីរៀបចំម្ហូបអាហារក្រៅពេល ឬភេសជ្ជៈធម្មតាខ្លះៗ សម្រាប់បុត្រ ធីតារបស់ខ្លួន ។ ហើយប្រសិនបើមាតាបិតាសិស្សជាអ្នកសេពសុរា ឬក៏ជក់បារីនោះ ព្រះ អង្គគួរតែដាស់តឿនពួកគាត់ ឱ្យចេះកាត់បន្ថយដោយស្ម័គ្រចិត្ត និងផ្តល់ប្រាក់សំចៃពីការកាត់ បន្ថយនោះ សម្រាប់ឧបត្ថម្ភឱ្យដល់កម្មវិធីមត្តេយ្យសាលារបស់ព្រះអង្គ ។ តាមវិធីនេះ មាតាបិតាសិស្ស មិនត្រឹមតែអាចជួយដល់បុត្រធីតារបស់ខ្លួន បានទៅរៀននៅមត្តេយ្យ-សាលាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយខ្លួនឯងផង និងកែលំអគុណភាពនៃការរស់នៅ ប្រចាំថ្ងៃ របស់គ្រួសារទាំងមូលផងដែរ ។

ដើម្បីអនុវត្តកម្មវិធីមត្តេយ្យសាលានេះ លក្ខណៈសម្បត្តិខាងកិរិតវប្បធម៌ វិជ្ជាជីវៈ

ផ្សេងៗ ឬផ្នែកអក្សរសាស្ត្ររបស់ដូនជី យើងត្រូវតែស្វាគមន៍ ប៉ុន្តែវាមិនមែនជាការចាំបាច់ពេកឡើយ ។ តាមរយៈនៃការនិទានរឿង និងវិធីមិនផ្លូវការដទៃទៀត ដូនជីអាចផ្តល់ការណែនាំក្នុងការប្រតិបត្តិខ្លួនដ៏សមរម្យត្រឹមត្រូវក្នុងការរស់នៅ មានដូចជា អនាម័យ កាតព្វ-កិច្ចចំពោះចាស់ទុំនិងអ្នកដទៃ ចរិយាធម៌ជាដើម ។ គេអាចដឹកនាំផ្លូវកុមារឱ្យរៀនសូធ្យបានច្រើនទៀត ទាក់ទងទៅនឹងបរិស្ថានរបស់វត្ត និងវត្តអារាម ។ ក្រៅពីនេះ មានសកម្មភាពខាងសាសនាដ៏សាមញ្ញៗ មានដូចជា ការបូជាផ្កា ការសូធ្យ ការនិទាន ដែលអាចលើកបង្ហាញនៅក្នុងទំរង់នៃការសំដែងរឿងខ្លីៗ ឬជាចំរៀង ដែលអាចទាក់ទាញអារម្មណ៍សិស្សឱ្យជក់ចិត្ត ។ សេវាកម្មបែបនេះ នឹងជួយលើកកំពស់កែលំអដល់ទំនាក់ទំនងដ៏សមស្របមួយ រវាងវត្ត និងសង្គម ហើយកុមារក៏នឹងបានអភិវឌ្ឍជាមួយនឹងជីវិត ដែលប្រកបដោយសុក្រឹតភាពខាងសាសនា ។ រាល់សកម្មភាពខាងលើនេះ ដូនជីនឹងទទួលបានការគោរពពីសង្គម ក្នុងឋានៈជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍមនុស្ស និងសង្គម-វប្បធម៌ ។

មត្តេយ្យសាលារបស់សហគមន៍វត្ត គ្រាន់តែជាសកម្មភាពគំរូមួយរបស់ដូនជី ដែលអាចចូលរួមចំណែកក្នុងការលើកកំពស់ និងកែលំអគុណភាពនៃការរស់នៅ តាមសហគមន៍ដែលរៀបចំ និងចាត់ចែងឡើងដោយវត្តរបស់ព្រះតេជព្រះគុណ ។ នៅមានការសិក្សា និងសកម្មភាពអនុវត្តផ្សេងទៀត ដែលគេអាចទទួលរ៉ាប់រងធ្វើ តាងនាមឱ្យព្រះធម៌ និងបរិស្ថាន ។

## ការអភិរក្សធម្មជាតិ គឺដើម្បីថែរក្សាគុណភាពជីវិតរបស់ប្រជាពលរដ្ឋ

❖ ព្រះពុទ្ធសាសនាមានទស្សនៈថា មនុស្សជាតិជាផ្នែកមួយនៃធម្មជាតិ ។ ដូច្នេះដោយការរំលោភ ឬកេងប្រវ័ញ្ចលើធម្មជាតិ នោះមានន័យថា មនុស្សនឹងរំលោភបំពាន ឬកេងប្រវ័ញ្ចលើខ្លួនឯងដែរ ។ ប្រសិនបើធម្មជាតិត្រូវគេបំផ្លាញ នោះមនុស្សលោក មិនអាចរស់រានមានជីវិតបានឡើយ ។ រាល់ជីវិត និងភាវៈទាំងឡាយនៅលើផែនដីនេះ រមែងតែមានអន្តរសម្ពន្ធនឹងគ្នា និងតែងមានលក្ខខណ្ឌរវាងគ្នាជានិច្ច ។ ព្រះសម្មាសម្ពុទ្ធ បានពន្យល់របៀបនៃកិច្ចការរបស់ព្រះធម៌យ៉ាងដូច្នេះថា: " **ធម្មោ ហវេ រក្ខតិ ធម្មចារឹ** " ដែលមានន័យថា : " *មនុស្សដែលការពារព្រះធម៌ ឬប្រព្រឹត្តស្របតាមព្រះធម៌ រមែងត្រូវបានព្រះធម៌ការពារ* " ។

រឿងនេះមានន័យថា ប្រសិនបើព្រះតេជព្រះគុណ-លោកអ្នកមិនដើរតាមគន្លងព្រះធម៌ទេ ឬក៏ប្រឆាំងនឹងព្រះធម៌ នោះក៏មានន័យថា ព្រះតេជព្រះគុណ-លោកអ្នក នឹងប្រឆាំងធម្មជាតិដែរ ហើយហៅរកការបំផ្លិចបំផ្លាញ សំរាប់ព្រះតេជព្រះគុណ-លោកអ្នកដោយខ្លួនឯង និងអ្នកដ៏ទៃទៀតជាមិនខានឡើយ ។ សញ្ញាណនេះ បានបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាងព្រះធម៌ សកម្មភាពរបស់មនុស្សជាតិ ហើយនិងបរិស្ថាន ។

❖ "**យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ** " ប្រែថា : "*បុគ្គលសាបព្រោះនូវពូជយ៉ាងណា រមែងទទួលនូវផលយ៉ាងនោះ* " ។

UNDP/ETAP

គម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ

This non-formal education manual was prepared by the NGO Working Group of the Monk Environmental Education Project (MEEP) in the Kingdom of Cambodia with technical assistance from UNDP's Environmental Technical Advisory Programme (ETAP) in Cambodia. The writing, editing, and printing of the manual was supported by UNDP/ETAP in collaboration with UNESCO-Cambodia.